# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌
លេខ ៨៧ វណ.បទជ-៩៩

# រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សូមជម្រាបមក

### លោក ប្រធានតុលាការ ខេត្តបន្ទាយមានជ័យ

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីពាក្យបណ្តឹងចុះថ្ងៃទី០៧-១២-៩៨ របស់ឈ្មោះ....ជាប្រធានអង្គការកុមារសង្គ្រោះខ្មែរតាំងនៅភូមិបាលិលេយ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ទីលំនៅៗផ្ទះលេខ១៥១ វិថីសហភាពសូវៀត សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។

តាមពាក្យបណ្តឹងដូចខាងលើ ម្ចាស់បណ្តឹងបានសុំឱ្យក្រសួងយុត្តិធម៌ ជួយអន្តរាគមន៍មកតុលាការខេត្តបន្ទាយមានជ័យ សុំឱ្យទទួលយកពាក្យបណ្តឹងរបស់ខ្លួនចុះថ្ងៃទី១០-១១-៩៨ និងពាក្យចុះថ្ងៃទី១១-១១-៩៨ យកទៅដោះស្រាយសម្រេចតាមផ្លូវតុលាការដោយអាងហេតុថា តាំងពីថ្ងៃដាក់ពាក្យនោះមក តុលាការខេត្តបន្ទាយមានជ័យពុំទាន់បានលើកយកបណ្តឹងរបស់ខ្លួន ទៅចាត់ការឱ្យខ្លួនតាមផ្លូវច្បាប់ទេ ហើយសាមីម្ចាស់បណ្តឹងបានភ្ជាប់ពាក្យទាំងពីច្បាប់នោះទៅក្រសួងយុត្តិធម៌ផង ។

ក្រោយពីក្រសួងយុត្តិធម៌បានពិនិត្យលើពាក្យបណ្តឹងទាំងពីរ និងសំណុំរឿងដែលតុលាការខេត្តបន្ទាយមានជ័យ បានបញ្ជូនទៅក្រសួងតាមលិខិតលេខ៣០៥ រប-៩៨ ចុះថ្ងៃទី២៥-១១-៩៨ ក្រសួងសូមណែនាំអំពីនីតិវិធីដែលតុលាការខេត្តបន្ទាយមានជ័យ ត្រូវចាត់ការលើពាក្យបណ្តឹងទាំពីរដូចតទៅ៖

-ពាក្យបណ្តឹងចុះថ្ងៃទី១០-១១-៩៨ តុលាការត្រូវចាត់ការជាពាក្យបណ្តឹងជំទាស់ជាតតិយជននឹងសាលក្រមលេខ៣៨ ចុះថ្ងៃទី១៣-០៥-៩៨ ជារឿងអង្គសេចក្តី រួចកោះហៅភាគីទាំអស់ ដែលមានផលប្រយោជន៍ពាក់ព័ន្ធក្នុងរឿងក្តីនេះមកធ្វើការផ្សះផ្សាធ្វើការស៊ើបអង្កេតបង្គាប់ឱ្យភាគីនីមួយៗ ជូនសំអាងការពារផលប្រយោជន៍របស់ខ្លួនតាមចំណុចនៃពាក្យបណ្តឹងសុំ ពាក្យបណ្តឹងសុំបន្ថែមឬពាក្យ បណ្តឹងតវ៉ាត ដែលភាគីទាំងអស់បានដាក់ចូលដល់តុលាការជាលាយល័ក្ខអក្សរ ឬតាមមាត់ទទេ ដែលត្រូវកត់ត្រាចូលក្នុងកំណត់ហេតុរបស់តុលាការ បន្ទាប់មកតុលាការត្រូវដាក់រឿងទៅជំនុំជម្រះដោយតុលាការត្រូវធ្វើការពិចារណាប្រៀបធៀបរវាងពាក្យសុំទាំងអស់ដែលមាន និងគ្មានភស្តុតាងទៅនឹងបញ្ញត្តិច្បាប់ហើយសម្រេចសេចក្តីតាមផ្លូវតុលាការដោយបើកផ្លូវប្តឹងឧទ្ធរណ៍ ។

**ចំណុចទី១** នៃពាក្យបណ្តឹង គឺម្ចាស់បណ្តឹងសុំលុបពាក្យ(ប្តីប្រពន្ធ) ចេញពីប័ណ្ណសម្គាល់កម្មសិទ្ធិលេខC៨: ០១៥២ និងពីប័ណ្ណសម្គាល់កម្មសិទ្ធិលេខC៨:០២២៧ ។ បើរកទៅឃើញថា ពុំមានអាពាហ៍ពិពាហ៍ជាមួយគ្នាមក តុលាការត្រូវសម្រេចសេចក្តីថា បង្គាប់ឱ្យសុរិយោដីខេត្តបន្ទាយមានជ័យលុបពាក្យថា (ប្តីប្រពន្ធ) ចេញពីប័ណ្ណសម្គាល់កម្មសិទ្ធទាំងពីរខាងលើ ហើយឱ្យចុះដាក់ពាក្យថា ( សហកម្មសិទ្ធិ ) ជំនួសវិញ ។ ផ្ទុយទៅវិញបើរកទៅឃើញថាឈ្មោះ...និងនាង.....មានសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវតាមច្បាប់តុលាការត្រូវសម្រេចសេចក្តីបដិសេធពាក្យបណ្តឹងរបស់ឈ្មោះ....ចោល ។

**ចំណុចទី២** សុំបដិសេធសាលក្រមលេខ៣៤ ចុះថ្ងៃទី១៣-០៥-៩៨ ត្រង់ចំណុចដែលអនុញ្ញាតឱ្យរឹបអូសសម្បត្តិទ្រព្យដាក់ធានា ។ បើតុលាការរកភស្តុតាងឃើញថា ពុំមែនជាទ្រព្យសម្បត្តិប្តី ប្រពន្ធជាមួយគ្នាទេ តុលាការត្រូវ

តែសម្រេចសេចក្តីបដិសេធចំណុចនេះចោលចេញពីសាលក្រម ហើយកដាក់ពាក្យរឹបអូសត្រឹមពាក់កណ្តាលនៃទ្រព្យសម្បត្តិនេះជំនួសវិញ ។ ផ្ទុយទៅវិញបើពុំមានភស្តុតាងបញ្ជាក់ដូចខាងលើនេះទេ តុលាការត្រូវសម្រេចសេចក្តីបដិសេធពាក្យបណ្តឹងរបស់ដើមចោទចោល ហើយតម្កល់តាមសេចក្តីសម្រេចនៃសាលក្រមលេខ៣៤ ចុះថ្ងៃទី១៣-០៥-៩៨ ទុកជាបានការដដែល។

**<u>ចំណុចទី៣</u>** សុំបដិសេធកំណត់ហេតុរឹបអូស កំណត់ហេតុលក់ឡាយឡុង ចុះថ្ងៃទី២៦-១០-៩៨ កំណត់ហេតុ ចុះថ្ងៃទី០៥-១១-៩៨ ដីកាសម្រេចលេខ១២៣ ដ.ស.រ ចុះថ្ងៃទី២៩-១០-៩៨ និងដីកាបង្គាប់លេខ ១២៤ ដ.ប ចុះថ្ងៃទី២៩-១០-៩៨ ចោល ។ ចំណុចនេះវាទាក់ទងទៅនឹងចំណុចទី១,ទី២ ដដែល គឺថាបើតុលាការរកទៅឃើញថាផ្ទះនិងដីលេខC៨:០១៥២ ពុំមែនជាទ្រព្យសម្បត្តិរួមរវាងឈ្មោះ...និងនាង....ឬបើទោះបីជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធក៏ដោយតែពុំមែនជាទ្រព្យដាក់បញ្ចាំទេ គឺពុំទាន់មានសេចក្តីសម្រេចណាមួយតម្រូវឱ្យរឹបអូសផ្ទះ និងដីលេខC៨:០១៥២ នេះទេ ហើយមានតែសាលក្រមលេខ៣៤ ចុះថ្ងៃទី១៣-៥-៩៨ ដែលអនុញ្ញាតឱ្យរឹបអូសតែដីលេខ C៨:០២២៧ ទេនោះ តែអ្នកអនុវត្តសាលក្រមមិនទៅរឹបអូសដីដែលមានសាលក្រមសម្រេចឱ្យរឹបអូស បែរជាទៅរឹបអូសវត្ថុផ្សេងទៅវិញនោះ គឺអ្នកអនុវត្តសាលក្រមធ្វើកិច្ចការរបស់ខ្លួនខុសពីសេចក្តីសម្រេចនៃសាលក្រមពោលគឺខុសច្បាប់ ។ ដូច្នេះតុលាការត្រូវសម្រេចបដិសេធកិច្ចការរបស់អ្នកអនុវត្តសាលក្រមនោះចោលទាំងអស់តាមពាក្យសុំរបស់ដើមចោទ ។ តែបើរកទៅឃើញថា អ្នកអនុវម្មសាលក្រមពុំបានអនុវត្តខុសពីខ្លឹមសារនៃសាលក្រមខាងលើនេះទេនោះ តុលាការត្រូវសម្រេចសេចក្តីបដិសេធពាក្យរបស់ដើមចោទចោល ។

**<u>ចំណុចទី៤+ទី៥</u>** អំពីការប្តឹងសុំទារសោហុយខូចខាតទ្រព្យសម្បត្តិ ខូចខាតកិត្តិយស និងសោហុយជំងឺចិត្ត ។ ករណីនេះបើតុលាការរកទៅឃើញថា ជនណាខ្លះដែលធ្វើឱ្យគេខូចខាតដោយអំពើរបស់ខ្លួន ជននោះត្រូវទទួលខុសត្រូវក្នុងករណីនេះ ដែលតុលាការត្រូវតែសម្រេចសេចក្តីតម្រូវឱ្យជនដែលមានកំហុសចេញសងទៅជនដែលរងគ្រោះតាមទំហំនៃការខូចខាត ។

ពាក្យបណ្តឹងទី២,ចុះថ្ងៃទី១១-១១-៩៨ សុំចូលទៅកាន់កាប់ផ្ទះសង់នៅលើដីលេខC៨:០១៥២ ជាបណ្តោះអាសន្ន ។ ពាក្យបណ្តឹងនេះ តុលាការត្រូវចាត់ការចុះបញ្ជីជារឿងក្តីកិច្ចការប្រញាប់ រួចចេញដីកាកោះហៅគូភាគីដែលពាក់ព័ន្ធមកជួបគ្នាក្នុងបន្ទប់ដ៏សមគួរណាមួយរបស់ចៅក្រមទទួលបន្ទុកដោះស្រាយរឿង ហើយធ្វើការសួរពិភាក្សាតទល់គ្រប់ភាគីដែលពាក់ព័ន្ធ និងឱ្យជូនភស្តុតាងហើយសម្រេសេចក្តីក្នុងពេលនោះ ឬនៅពេលក្រោយដ៏ខ្លីជាការប្រញាប់ប្រសិនបើមានភាគីណាមួយសុំពន្យាពេលដើម្បីរកភស្តុតាងជូនចៅក្រម កិច្ចការបញ្ជាប់សម្រាប់ដាក់បន្ទុកលើពាក្យបណ្តឹង ឬដោះបន្ទុកអំពីពាក្យចោទប្រកាន់ តែត្រូវណាត់ពេលវេលាសវនាការជាថ្មីដោយឱ្យភាគីដែលវត្តមានផ្តិតមេដៃលើកំណត់ហេតុក្នុងសៀវភៅ ហើយកោះភាគីដែលអវត្តមាន ។ ទន្ទឹមនឹងនេះបើចៅក្រមកិច្ចការប្រញាប់រកទៅឃើញថារឿងនេះមានភស្តុតាងបញ្ជាក់ថា អ្នកអនុវត្តសាលក្រម បានចាត់ការរឹបអូសផ្ទះជាកម្មសិទ្ធិដែលពុំមានពាក់ព័ន្ធក្នុងសាលក្រម ដែលបានចង្អុលឱ្យរឹបអូសចំផ្ទះនោះទេ ចៅក្រមកិច្ចការប្រញាប់ត្រូវចេញដីកាកិច្ចការប្រញាប់ប្រគល់ផ្ទះនោះទៅឱ្យម្ចាស់កម្មសិទ្ធវិញ ហើយសម្រេចសេចក្តីប្រានចោលនូវពាក្យសុំបង្អង់រឿងរបស់ភាគីអ្នកសុំបង្អង់នោះចោល ហើយសម្រេចសេចក្តីអនុញ្ញាតឱ្យដើមចោទចូលកាន់កាប់ផ្ទះរបស់ខ្លួនវិញភ្លាម។ សេចក្តីសម្រេចកិច្ចការប្រញាប់នេះ បើកឱ្យប្តឹងឧទ្ធរណ៍ ដូចកិច្ចការបញ្ជាប់ផ្សេងៗទៀត ។

ទន្ទឹមនឹងពេលនេះ ក្រសួងយុត្តិធម៌ សូមរំលឹកលោកប្រធាន និងតម្រូវបន្ថែមថា តាមសេចក្តីបង្គាប់របស់ក្រសួងយុត្តិធម៌លេខ ១១៧ - សរ,រ-៩៧ ចុះថ្ងៃទី៣១-០១-៩៧ ក្រសួងយុត្តិធម៌បានសម្រេប្រគល់សមត្ថកិច្ច ជូនលោកព្រះរាជអាជ្ញាដឹកនាំអនុវត្តដោយផ្ទាល់ជាបណ្តោះអាសន្ននូវសេចក្តីសម្រេចទាំងអស់ និងដីកាផ្សេងៗទៀតរបស់តុលាការគ្រប់ជាន់ថ្នាក់ ក្នុងរង្វង់សមត្ថកិច្ចដែនដីរបស់ខ្លួនទំរាំមានច្បាប់ កំណត់អំពីបញ្ហានេះប្រសិនបើមានការស្នើសុំត្រឹមត្រូវតាមច្បាប់ ពីអ្នកឈ្នះ ឬពីអ្នកទទួលសិទ្ធិពីអ្នកឈ្នះក្តី ។

ប្រធានតុលាការ ឬចៅក្រមដែលប្រធានតុលាការចាត់តាំងឱ្យទទួលភារកិច្ចក្នុងរឿងក្តីណាមួយមានតួនាទីជាអ្នកត្រួតពិនិត្យ រួចវិនិច្ឆ័យសេចក្តី នៅពេលណាដែលមានពាក្យបណ្តឹងតវ៉ាអំពីចំណុចខ្វះខាតនៃការអនុវត្តសាលក្រម ឬសាលដីកាពីជនដែលត្រូវរឹបអូសពីម្ចាស់បំណុលនៃជនដែលត្រូវរឹបអូស ឬ ពីតតិយជនណាមួយដែលមានផលប្រយោជន៍ក្នុងរឿងក្តីនោះ ។

ដូច្នេះចាប់ពីពេលនេះតទៅ សូមលោកប្រធានឈប់ដឹកនាំអនុវត្តសាលក្រម ឬសេចក្តីសម្រេចផ្សេងៗ ដោយខ្លួនឯង ឬចាត់ចៅក្រមណាមួយឱ្យនុវត្តជំនួសលោកប្រធានតទៅទៀត ដោយទុកសមត្ថកិច្ចជូនលោកព្រះរាជអាជ្ញាចាត់ការដឹកនាំអនុវត្តចាប់តាំពីសេចក្តីជូនដំណឹងរហូតដល់មានការកំណត់ជាថ្មី ដោយយោងទៅតាមការកំណត់នៃច្បាប់ស្តីវិធីអនុវត្តសាលក្រមរដ្ឋប្បវេណី បើពុំគោរពតាមសេចក្តីបង្គាប់របស់ក្រសួងដូចខាងលើទេនោះកិច្ចការអនុវត្តសាលក្រមនៅតុលាការខេត្តបន្ទាយមានជ័យ ត្រូវទុកជាមោឃៈព្រោះខុសសមត្ថកិច្ចមុនពេលក្រសួងបានកំណត់ក្នុងសេចក្តីបង្គាប់ខាងលើ ប្រសិនបើមានភាគី ឬអ្នកទទួលសិទ្ធិពីភាគី ឬតតិយជនមានផលប្រយោជន៍ប្តឹងតវ៉ា ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩

**រដ្ឋមន្ត្រី**

**អ៊ុក វីធុន**

<u>ចម្លងជូន</u>

-តុលាការ និងអយ្យការខេត្ត ក្រុង

-ដើម្បីជ្រាប